# សេចក្តីថ្លែងការណ៍រួម

## ស្តីពី

## ការព្រួយបារម្ភជុំវិញករណីចាប់ខ្លួនផ្នែកនយោបាយ នៅខេត្តកំពង់ធំ

**គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា** ដែលជាសម្ព័ន្ធអង្គការ-សមាគមមិនមែនរដ្ឋាភិបាលក្នុងស្រុក ចំនួន ២១, **គណៈកម្មាធិការខុមហ្វ្រែល** មានសមាជិក ចំនួន ១០ អង្គការ-សមាគម **និង គណៈកម្មាធិការ និកហ្វិច** មានសមាជិកចំនួន ៧ អង្គការ-សមាគម មានការព្រួយបារម្ភជាខ្លាំង ចំពោះការកើតឡើងជាបន្តបន្ទាប់នូវអំពើគំរាមកំហែង ការចាប់ឃុំខ្លួនផ្នែកនយោបាយ ដោយមានការប្រើប្រាស់ប្រព័ន្ធតុលាការជាឧបករណ៍នយោបាយផង ខណៈពេលដែលការបោះឆ្នោតជាតិ នាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ខិតជិត មកដល់។

កាលពីថ្ងៃទី១៨ មីនា ២០០៨ វេលា ម៉ោង ៩:០០ ព្រឹក លោក **ទួត សារ៉ន** មេឃុំពង្រ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ត្រូវបានក្រុមប៉ូលីសដែលដឹកនាំដោយលោកអធិការស្រុកបារាយណ៍ ចាប់ខ្លួននៅតាមផ្លូវមុំផ្សារទួលគ្រើល ស្រុកបារាយណ៍ ដោយពុំមានបង្ហាញដីកានាំខ្លួននោះទេ មន្ត្រីប៉ូលិសបានអះអាងថា ការនាំខ្លួននេះធ្វើតាមដីការបស់តុលាការខេត្តកំពង់ធំក៏ដោយចុះ។ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៨ ប៉ូលិសក៏បានបញ្ជូនខ្លួន លោក ទួត សារ៉ន មកកាន់ស្នងការ និង តុលាការខេត្តកំពង់ធំ។ ហើយមានការតាមរកចាប់ខ្លួនសកម្មជនគណបក្ស សម រង្ស៊ី ចំនួន ៣ នាក់ ផ្សេងទៀត ដែលមាន លោក **ថន ឫទ្ធី** ជាអនុប្រធាន គណបក្ស សម រង្ស៊ី ប្រចាំខេត្តកំពង់ធំ, លោក **ម៉ែន វណ្ណៈ** និង លោក **ហួ សារ៉ាត់**។

អង្គការមិនមែនរដ្ឋាភិបាលកត់សំគាល់ឃើញថា ករណីខាងលើនេះត្រូវបានអ្នកនយោបាយមួយចំនួន ប្រើប្រាស់សំរាប់ទាញយកផលចំណេញនូវប្រយោជន៍នយោបាយ។ ករណីចាប់ខ្លួនដែលមានការពាក់ព័ន្ធទៅនឹងការចោទប្រកាន់ពីបទបង្ខាំងមនុស្សដោយខុសច្បាប់នេះ អង្គការមិនមែនរដ្ឋាភិបាលយើងខ្ញុំក៏បានទទួលពាក្យបណ្តឹងពីភាគីទាំងពីរផងដែរ ហើយយើងបានធ្វើការស៊ើបអង្កេតដោយយកចិត្តទុកដាក់ និង ឈរលើភាពឯករាជ្យ ដោយមិនលំអៀង ។ ចំពោះករណីចោទប្រកាន់លើ លោក **ទួត សារ៉ន** ពីបទបង្ខាំងអ្នកស្រី **ទឹម ណន** មិនសមហេតុផលទេ ពីព្រោះយើងបានរកឃើញថា ការធ្វើដំណើររបស់អ្នកស្រី **ទឹម ណន** ពីខេត្តកំពង់ធំមកភ្នំពេញ តាមរថយន្តរបស់លោក **ទួត សារ៉ន** ដោយរួមដំណើរជាមួយលោក **ហួ សារ៉ាត់** និង លោក **ម៉ែន វណ្ណៈ** ក្នុងពេលធ្វើដំណើរតាមរថយន្តនោះ អ្នកស្រី **ទឹម ណន** ពុំត្រូវបានមនុស្សទាំងបីនាក់នោះដកហូតទូរស័ព្ទដៃរបស់អ្នកស្រីទេ ហើយអ្នកស្រីនៅមានលទ្ធភាពនិយាយទូរស័ព្ទជាមួយលោក **សុក ផេង** បាន។ នៅពេលអ្នកស្រី **ទឹម ណន** ស្នាក់នៅផ្ទះលោក **ថន ឫទ្ធី** ចំនួនមួយយប់ និង ការស្នាក់នៅក្នុងផ្ទះ

សុវត្ថិភាពរបស់អង្គការលីកាដូ ចំនួន ២ យប់ រួមទាំងការស្នាក់នៅជាមួយលោក **សុក ផេង** ផងនោះ អ្នកស្រីត្រូវបានអ្នកទាំងនោះទទួលអោយស្នាក់នៅ និង ផ្គត់ផ្គង់ម្ហូបអាហារ ថ្នាំពេទ្យ ដូចជាភ្ញៀវធម្មតា ដោយគ្មានការដាក់បង្ខាំង ឬ ចាក់សោរក្នុងបន្ទប់ ឬ មានការយាមកាមពីក្រុមប្រដាប់អាវុធណាមួយនោះឡើយ។ ទាំងនេះជាការបង្ហាញឱ្យឃើញថា អ្នកស្រី **ទឹម ណន** ពុំមានការបាត់បង់នូវសិទ្ធិសេរីភាពរបស់ខ្លួនក្នុងការទំនាក់ទំនងជាមួយមិត្តភក្តិ និង ក្រុមគ្រួសារនោះទេ។ ដូចនេះ ទាំងការធ្វើដំណើរ និង ការស្នាក់នៅរបស់អ្នកស្រី **ទឹម ណន** ពុំមានចំណុចណាមួយ ដែលជាធាតុផ្សំបញ្ជាក់ថា អ្នកស្រី **ទឹម ណន** ត្រូវបានអ្នកណាម្នាក់ធ្វើការបង្ខាំង ឬ ឃាត់ខ្លួនអ្នកស្រីឡើយ។

អង្គការមិនមែនរដ្ឋាភិបាល សូមអំពាវនាវដល់ប្រមុខរាជរដ្ឋាភិបាល ជាពិសេសអាជ្ញាធរមានសមត្ថកិច្ច មេត្តាធ្វើការស៊ើបអង្កេតឡើងវិញ ទៅលើការចាប់ខ្លួន និង ការស្វែងរកការចាប់ខ្លួន ក្នុងនាមរដ្ឋាភិបាល ដោយឈរលើគោលការណ៍អព្យាក្រិត្យ និង មិនលំអៀងទៅលើគណបក្សនយោបាយណាមួយ ដើម្បីផ្តល់ភាពយុត្តិធម៌ដល់អ្នកដែលត្រូវបានចាប់ខ្លួន និង អ្នកដែលកំពុងត្រូវបានស្វែងរកចាប់ខ្លួន។ ជាមួយគ្នានេះផងដែរ អង្គការមិនមែនរដ្ឋាភិបាល ក៏សូមអំពាវនាវដល់អ្នកនយោបាយគ្រប់គណបក្ស មេត្តាធ្វើយ៉ាងណា គោរពគ្នាទៅវិញទៅមកក្នុងសេចក្តីថ្លៃថ្នូរ និង មានភាពចាស់ទុំខាងនយោបាយ ដើម្បីអោយការបោះឆ្នោតជាតិខាងមុខនេះ ប្រព្រឹត្តទៅដោយស្មើភាព និង គ្មានអំពើហិង្សាខាងនយោបាយ។

ភ្នំពេញ, ថ្ងៃទី២៧ ខែមិនា ឆ្នាំ២០០៨

<u>សំរាប់ព័ត៌មានបន្ថែម សូមទាក់ទង:</u>


| | | |
|---|---|---|
| - លោក **នី ចរិយា** | ប្រធានផ្នែកស៊ើបអង្កេត សមាគមអាដហុក | ទូរស័ព្ទលេខ: ០១១ ២៧ ៤៩ ៥៩ |
| - លោក **សុក សំអឿន** | នាយកប្រតិបត្តិ អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា | ទូរស័ព្ទលេខ: ០១២ ៩០១ ១៩៩ |
| - លោក **គល់ បញ្ញា** | នាយកប្រតិបត្តិ ខុមហ្វ្រែល | ទូរស័ព្ទលេខ : ០១២ ៩៤២ ០១៧ |
| - លោក **ហង្ស ពុទ្ធា** | នាយកប្រតិបិត្តិ និកហ្វិច | ទូរស័ព្ទលេខ : ០១២ ៩៥៩ ៦៦៦ |